# កម្មវិធីអភិរក្សសត្វខ្លាធំ នៅកម្ពុជា
# Cambodia Tiger Conservation Program

## លទ្ធផលនៃការសំភាសន៍អ្នកប្រមាញ់លើកទី ២
## Results of Second Interview Survey of Hunters



CAT ACTION TREASURY

THE NATIONAL FISH AND WILDLIFE FOUNDATION

SAVE THE TIGER FUND

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

≈≈≈≈≈

ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ

នាយកដ្ឋាន រុក្ខា-ប្រមាញ់

ការិយាល័យការពារសត្វព្រៃ

# របាយការណ៍

# លទ្ធផលសំភាសន៍អ្នកប្រមាញ់លើកទី២

ចាប់ពីថ្ងៃទី ១៧ ឧសភា ១៩៩៩ ដល់ ថ្ងៃទី ០៤ កក្កដា ១៩៩៩


ដោយ :

- លោក ត្រី ម៉ះផល
- លោក រ័ត្ន ប៊ុនធឿន
- លោក ស៊ិន ប៉ូលីន
- លោក អ៊ុក គឹមសាន
- លោក អ៊ុច សីហា
- កែសំរួលដោយ : លោក ស៊ុន ហ៊ាន


ខែមិថុនា ឆ្នាំ២០០០

# មាតិកា

≈≈≈


- សេចក្តីថ្លែងអំណរគុណ
- សេចក្តីសង្ខេប

| | ទំព័រ |
|---|---|
| **I- សេចក្តីផ្តើម :** | ១ |
| .ស្ថានភាពទូទៅសត្វព្រៃនៅកម្ពុជា | ១ |
| .លទ្ធផលនៃការធ្វើសំភាសន៍លើកទី១ | ២ |
| .មូលហេតុនៃការធ្វើសំភាសន៍លើកទី២ | ៣ |
| .ការជ្រើសរើសតំបន់ស្រាវជ្រាវ | ៣ |
| **II- ស្ថានភាពសេដ្ឋកិច្ចសង្គម:** | ៣ |
| ២.១- ប្រជាជន | ៣ |
| ២.២- មុខរបរ | ៤ |
| ២.៣-សុខាភិបាល | ៤ |
| ២.៤-ការអប់រំ | ៥ |
| **III- ស្ថានភាពសត្វខ្លាធំនៅក្នុងតំបន់ :** | ៥ |
| ៣.១- វត្តមាន | ៥ |
| ៣.២- ភាពគំរាមកំហែង | ៧ |
| ៣.២.១-ការកាប់បំផ្លាញព្រៃឈើ | ៧ |
| ៣.២.២-ការប្រមាញ់ | ៧ |
| ៣.៣- ការធ្វើអាជីវកម្ម | ៨ |
| **IV- វិធីសាស្ត្រ :** | ៩ |
| ៤.១- ការសំភាសន៍ | ៩ |
| ៤.២- ទីកន្លែងសំភាសន៍ | ៩ |
| ៤.៣- ការជ្រើសរើសព្រាន | ១០ |
| ៤-៤-មូលហេតុនៃការប្រើប្រាសវិធីសាស្ត្រសំភាសន៍ | ១៤ |

**V- លទ្ធផលនៃការសិក្សាសង្ខេប :** ១៤

**៥.១. ភូមិភាគឥសាន** ១៥

៥.១.១: ជួបខ្លា ១៥

៥.១.២ : ឃើញដាន ១៥

៥.១.៣: ទិន្នន័យខ្លាដែលបានសំលាប់ ១៦

៥.១.៤: ប្រភេទសត្វប្រមាញ់ ១៧

៥.១.៥: ការវាយប្រហាររបស់សត្វខ្លាមកលើមនុស្ស និង សត្វស្រុក ១៩

៥.១.៦: ប្រភេទសត្វដែលប៉ះពាល់ដល់ប្រពៃណី-ទំនៀមទំលាប់ ២០

៥.១.៧: ឧបករណ៍ប្រមាញ់ ២២

៥.១.៨: ការបែងចែកផលប្រមាញ់ ២២

៥.១.៩: សារៈសំខាន់នៃការប្រមាញ់ចំពោះគ្រួសារ ២៤

៥.១.១០: ចំណេះដឹងរបស់ព្រានពីនយោបាយសត្វព្រៃរបស់រដ្ឋាភិបាល ២៤

៥.១.១១: ចំណេះដឹងរបស់ព្រានទៅលើការអភិរក្ស ២៤

៥.១.១២: ការវាយតំលៃរបស់ព្រានលើស្ថានភាពសត្វព្រៃ ២៥

**៥.២. ភូមិភាគខាងត្បូងបឹងទន្លេសាប** ២៧

៥.២.១: ជួបខ្លា ២៧

៥.២.២ : ឃើញដាន ២៨

៥.២.៣: ទិន្នន័យខ្លាដែលបានសំលាប់ ២៩

៥.២.៤: ប្រភេទសត្វប្រមាញ់ ៣១

៥.២.៥: ការវាយប្រហាររបស់សត្វខ្លាមកលើមនុស្ស និង សត្វស្រុក ៣២

៥.២.៦: ប្រភេទសត្វដែលប៉ះពាល់ដល់ប្រពៃណី-ទំនៀមទំលាប់ ៣៣

៥.២.៧: ឧបករណ៍ប្រមាញ់ ៣៥

៥.២.៨: ការបែងចែកផលប្រមាញ់ ៣៩

៥.២.៩: សារៈសំខាន់នៃការប្រមាញ់ចំពោះគ្រួសារ ៤០

៥.២.១០: ចំណេះដឹងរបស់ព្រានពីនយោបាយសត្វព្រៃរបស់រដ្ឋាភិបាល ៤០

៥.២.១១: ចំណេះដឹងរបស់ព្រានទៅលើការអភិរក្ស ៤១

៥.២.១២: ការវាយតំលៃរបស់ព្រានលើស្ថានភាពសត្វព្រៃ ៤២

**៥.៣. ភូមិភាគខាងជើងបឹងទន្លេសាប** ៤៤
៥.៣.១: ជួបខ្លា ៤៤
៥.៣.២ : ឃើញដាន ៤៤
៥.៣.៣: ទិន្នន័យខ្លាដែលបានសំលាប់ ៤៥
៥.៣.៤: ប្រភេទសត្វប្រមាញ់ ៤៥
៥.៣.៥: ការវាយប្រហាររបស់សត្វខ្លាមកលើមនុស្ស និង សត្វស្រុក ៤៧
៥.៣.៦: ប្រភេទសត្វដែលប៉ះពាល់ដល់ប្រពៃណី-ទំនៀមទំលាប់ ៤៧
៥.៣.៧: ឧបករណ៍ប្រមាញ់ ៤៩
៥.៣.៨: ការបែងចែកផលប្រមាញ់ ៥០
៥.៣.៩: សារៈសំខាន់នៃការប្រមាញ់ចំពោះគ្រួសារ ៥១
៥.៣.១០: ចំណេះដឹងរបស់ព្រានពីនយោបាយសត្វព្រៃរបស់រដ្ឋាភិបាល ៥២
៥.៣.១១: ចំណេះដឹងរបស់ព្រានទៅលើការអភិរក្ស ៥៣
៥.៣.១២: ការវាយតំលៃរបស់ព្រានលើស្ថានភាពសត្វព្រៃ ៥៣
**VI- សន្និដ្ឋាន :** ៥៥
៦.១- សត្វខ្លា ៥៥
៦.២- សត្វព្រៃទូទៅ ៥៥
៦.៣- ព្រាន ៥៦
៦.៤- ប្រសិទ្ធិភាពនៃការអភិរក្សសត្វខ្លា ៥៧
**VII- អនុសាសន៍ :** ៥៨
៧.១- បន្ទាន់បំផុត ៥៨
៧.២- សំរាប់អនាគត ៥៩

======================

=======

==

# បញ្ជីវិចិត្ររូប

ទំព័រ

**រូបថត**


១-ឧបករណ៍ អន្ទាក់សំរាប់ដាក់សត្វខ្លា ប្រើស ជ្រូក................(ខេត្តមណ្ឌលគិរី-កោះកុង) ២៣ និង ៣៩

២-សកម្មភាពសំភាសន៍ព្រាននៅក្នុង ខេត្តក្រចេះ ២៦

៣- សកម្មភាពសំភាសន៍ព្រាននៅក្នុង ខេត្តកោះកុង ៤៣

៤- សកម្មភាពសំភាសន៍ព្រាននៅក្នុង ខេត្តសៀមរាប ៥៤


**តារាង**


១-បញ្ជីឈ្មោះព្រានដែលបានសំភាសន៍ដោយបញ្ជាក់អំពីមុខរបរ ទីលំនៅនិង បទពិសោធន៍ ១១-១៣

២-តារាងបញ្ជាក់អំពីកំរិតឆន្ទះរបស់ព្រានទៅលើប្រភេទសត្វដែលត្រូវប្រមាញ់ (ខេត្តក្រចេះ-មណ្ឌលគិរី) ១៧-១៨

៣- តារាងបញ្ជាក់អំពីកំរិតឆន្ទះរបស់ព្រានទៅលើប្រភេទសត្វដែលត្រូវប្រមាញ់ (ខេត្តកោះកុង) ៣១-៣២

៤- តារាងបញ្ជាក់អំពីកំរិតឆន្ទះរបស់ព្រានទៅលើប្រភេទសត្វដែលត្រូវប្រមាញ់ (ខេត្តសៀមរាប-ព្រះវិហារ) ៤៦-៤៧


**ឧបសម្ព័ន្ធ**


*ឧបសម្ព័ន្ធ១*: បញ្ជីរសំនួរសំភាសន៍ព្រានប្រមាញ់ស្តីពី ការស្ទង់ប៉ាន់ស្មានចំនួនសត្វខ្លាធំនៅប្រទេសកម្ពុជា លើកទី១

*ឧបសម្ព័ន្ធ២*: បញ្ជីរសំនួរស្តីអំពី ការស្ទង់ប៉ាន់ស្មានចំនួនសត្វខ្លាធំនៅប្រទេសកម្ពុជា ដែលត្រូវបំពេញបែបបទដោយ មន្ត្រីរុក្ខា-ប្រមាញ់មូលដ្ឋាន

*ឧបសម្ព័ន្ធ៣*: សំរង់បែបបទសំភាសន៍ព្រានប្រមាញ់លើកទី២

*ឧបសម្ព័ន្ធ៤*: តារាងបញ្ជាក់អំពីពេលវេលានិង ទីកន្លែងដែលព្រានបានជួប ជួបដាននិង សំលាប់ខ្លានៅខេត្តក្រចេះនិង មណ្ឌលគិរី ក្នុងឆ្នាំ ១៩៩៨-១៩៩៩

*ឧបសម្ព័ន្ធ៥*: តារាងបញ្ជាក់អំពីពេលវេលានិង ទីកន្លែងដែលព្រានបានជួប ជួបដាននិង សំលាប់ខ្លានៅខេត្តកោះកុង ក្នុងឆ្នាំ ១៩៩៨-១៩៩៩

*ឧបសម្ព័ន្ធ៦*: តារាងបញ្ជាក់អំពីពេលវេលានិង ទីកន្លែងដែលព្រានបានជួប ជួបដាននិង សំលាប់ខ្លានៅខេត្តព្រះវិហារនិង សៀមរាប ក្នុងឆ្នាំ ១៩៩៨-១៩៩៩

# សេចក្ដីថ្លែងអំណរគុណ

≈≈≈≈≈

យើងខ្ញុំទាំងអស់គ្នាជាក្រុមស្រាវជ្រាវសត្វខ្លាកម្ពុជា (Cambodian Tiger Research Team) សូមថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អ្នកស្រី Kristin Nowell ប្រធានអង្គការ CAT (Cat Action Treasury) ដែលបានផ្ដួចផ្ដើមគំនិត និង យកចិត្តទុកដាក់ក្នុងការរៀបចំអភិរក្សសត្វខ្លាធំនៅកម្ពុជា។ នេះជាលើកទីមួយ ហើយដែលប្រទេសកម្ពុជា បានទទួលការចាប់អារម្មណ៍ពីអន្តរជាតិ លើការបាត់បង់ប្រភេទ សត្វខ្លាធំ ហើយថែមទាំង បានឧបត្ថម្ភទាំងបច្ចេកទេស និង ថវិការដើម្បីឱ្យការងារជំហ៊ានទី២ នេះ បានប្រព្រឹត្តទៅដោយ ជោគជ័យ ។

ជាមួយគ្នានេះដែរក៏សូមថ្លែងអំណរគុណដល់លោក HunterWeiller អ្នកសំរបសំរួលគំរោងអង្គការ CAT ដោយលោកបានធ្វើកិច្ចការងារដោយផ្ទាល់ ក្នុងមួយរយៈពេលដែលលោកមានវត្តមាននៅកម្ពុជា ពិសេសបានធ្វើឱ្យពិភពលោកមានកង្វល់តាមរយៈសារពត៌មានអន្តរជាតិ ចំពោះអង្គការអភិរក្សសត្វព្រៃនានា លើរបាយ និង ភាពគំរាមកំហែងសត្វខ្លានៅកម្ពុជា ។

ទន្ទឹមគ្នានេះដែរក៏សូមថ្លែងអំណរគុណចំពោះលោក ស៊ុន ហ៊ាន អនុប្រធានការិយាល័យការពារសត្វព្រៃ កំពុងបំពេញការសិក្សាថ្នាក់អនុបណ្ឌិតនៅសកលវិទ្យាល័យ Minnesota សហរដ្ឋអាមេរិក ដោយលោកបានចំណាយពេលវេលាដ៏មានតំលៃក្នុងការទំនាក់ទំនងគំរោងថវិកាក៏ដូចជាការផ្ដល់គំនិតនិងការគ្រប់គ្រងគំរោងនេះរហូតដល់ទីបំផុត។

សូមថ្លែងអំណរគុណចំពោះលោក ប្រធានការិយាល័យការពារ សត្វព្រៃ និង ថ្នាក់ដឹកនាំនាយកដ្ឋានរុក្ខា-ប្រមាញ់ដែលបានសំរួលការងារដល់ក្រុមយើងខ្ញុំ តាំងពីដើម រហូតដល់បញ្ចប់ ការងារ ។

ដូចនេះដែរ យើងខ្ញុំសូមថ្លែង អំណរគុណចំពោះ អាជ្ញាធរខេត្ត ក្រចេះ ស្ទឹងត្រែង មណ្ឌលគីរី កោះកុង ពោធិសាត់ ព្រះវិហារ និងខេត្តសៀមរាប ដែលបានគាំទ្រដល់គំរោងការងារនេះ និងយកចិត្តទុកដាក់ជួយសំរួលការងារដោយផ្ដើមតាំងពីការបើកសិក្ខាសាលានៅតាមបណ្ដាខេត្ត និងជាពិសេសជួយសហការ ដើម្បីធានាសន្តិសុខដល់ក្រុម យើងខ្ញុំ ក្នុងរយៈពេលចុះបំពេញភារកិច្ច ។

ជាចុងក្រោយក៏សូមអរគុណចំពោះកញ្ញាជា សុណារីមន្ត្រីការិយាល័យការពារសត្វព្រៃ ដែលបានជួយរៀបចំឯកសារ វាយកុំព្យូទ័រ តាំងពីដើមរហូតដល់បញ្ចប់ ដើម្បីចងក្រងជាសៀវភៅនេះ ។

❀❀❀

# សេចក្តីសង្ខេប

≈≈≈≈≈


ការប្រមូលពត៌មានសត្វខ្លាធំនៅទូទាំងប្រទេស តាមរយៈការសំភាសន៏លើព្រានលើកនេះ ជាជំហានទី២ ក្រោយពីការសំភាសន៏ជំហានទី១ ក្នុងឆ្នាំ ១៩៩៧ មក ។ គោលបំណងនៃការសំភាសន៏នេះ បានចាប់ផ្តើមក្រោយពីបានបើកអង្គសិក្ខាសាលា ស្តីពីការអភិរក្សសត្វខ្លាធំនៅក្នុងខេត្តទាំង ៦ រួចមក គឺដើម្បីប្រមូលពត៌មានឱ្យបានគ្រប់គ្រាន់បន្ថែមលើការសំភាសន៏ជំហានទី១ថាតើតួលេខសត្វខ្លាធំមានការប្រែប្រួលក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះយ៉ាងណានិងដើម្បីផ្សារភ្ជាប់សកម្មភាពអភិរក្សជាមួយនឹងព្រានក្នុងតំបន់ រួចឈានទៅធ្វើកិច្ចសហការក្នុងដំណើរយូរអង្វែង ។

ការសំភាសន៏បានដឹកនាំធ្វើខេត្ត ៥ មាន ខេត្តមណ្ឌលគិរី ក្រចេះ ព្រះវិហារ សៀមរាប និង កោះកុង ដែលជាតំបន់បង្ហាញសក្តានុពលខ្ពស់សំរាប់សត្វខ្លា ។ ដោយឡែកខេត្តពោធិសាត់ ពុំទាន់បានដឹកនាំធ្វើការសំភាសន៏ព្រោះពេលវេលាពុំអនុគ្រោះ ។

ក្នុងចំណោមខេត្តខាងលើ យើងបានធ្វើការសំភាសន៏លើព្រានចំនួន ៧១នាក់ ដែលស្ថិតក្នុងស្រុក ១៧ ក្នុងនោះមានការរៀបចំទំរង់សំនួរយ៉ាងលំអិតមួយ ពិសេសផ្តោតលើពត៌មានសត្វខ្លាធំ និង ពត៌មានប្រភេទសត្វមានដោយកម្រមួយចំនួនទៀតមាន : ក្តាន់ (Cervus schomburgki ) រមាស (Javan rhinoceros) ជ្រូកទឹក (Tapirus indicus) លំដាប់ពានរជាតិ (Primates) ពង្រូល (Manis javanica) ខ្ទីងវល្លី (Pseudonovibos spiralis) ឈ្លូសយក្ស (Megamuntiacus vuguangensis) គ្រួសារសំពោច (Viverridac) ភេរោមច្រមុះ (Lutra sumtrana) និង ប្រភេទ (Prionodon pardicolor) ដើម្បីចង់ដឹងពីវត្តមាន ថាតើវាមាននៅ ឬអាចកើតមានលើតំបន់ទាំងនោះ ។ភ្ជាប់ជាមួយនេះដែរទំរង់សំភាសន៏ក៏បានលើកជាសំនួរទាក់ទង នឹងជីវភាពរបស់ព្រានពីផលចំណូលបានពីការបរបាញ់ ពីចំណេះដឹងផ្សេងៗលើសត្វព្រៃមាន ចំណេះដឹងផ្នែកច្បាប់សត្វព្រៃរបស់រដ្ឋាភិបាល ទស្សនៈលើការអភិរក្សសត្វ ក្នុងតំបន់សារៈប្រយោជន៏សត្វព្រៃចំពោះមូលដ្ឋាន និង ស្ទាបស្ទង់ពីទស្សនៈផ្ទាល់របស់ព្រាន និង មតិប្រតិកម្មជុំវិញការអភិរក្សសត្វខ្លាធំ ។

ក្រោយពីបញ្ចប់ដំណើរការសំភាសន៏តាមបណ្តាខេត្តខាងលើ យើងប្រមូលបានទិន្នន័យដូចខាងក្រោម :

- ប្រភេទសត្វខ្លាធំបានទទួលរងគ្រោះច្រើនជាងគេ និង ថយចុះជាងបណ្តាឆ្នាំមុនៗ ព្រោះវាមានតំលៃផ្នែកពាណិជ្ជកម្មខ្ពស់ ក្នុងនោះខ្លាត្រូវបានប្រមាញ់រវាងឆ្នាំ ១៩៩៨-៩៩ មាន ៦១ក្បាល ( បាញ់យកតែស្បែក ឆ្អឹង ចំនួន ៥៥ក្បាល និង ចាប់កូន ៦ក្បាល) និងនៅមានមួយចំនួនទៀតពុំបានទទួលពត៌មាន ដូចជាព្រានមកពីតំបន់ ផ្សេងៗ

ព្រានពុំបានសំភាសន៍ ....  ។ល។ ព្រោះព្រានដែលបានសំភាសន៍គឺជាអ្នកមានលំនៅដ្ឋានអចិន្ត្រៃយ៍ដើម្បីងាយស្រួលកិច្ចសហការនាពេលខាងមុខ ។

- ក្នុងចំណោមព្រានខាងលើ មានទេពកោសល្យខុសៗគ្នាតាមតំបន់ក្នុងការប្រើប្រាស់ ឧបករណ៍ប្រមាញ់មានកាំភ្លើង (កាំភ្លើងស្វ័យប្រវត្តិ និង ឆ្នៃ) អន្ទាក់ អង្គប់ និង ឆ្កែ អ្នកខ្លះប្រមាញ់សត្វធំៗមាន ខ្លា ដំរី ទន្សោង ខ្ទីង ខ្លះរកតែប្រភេទសត្វតូចៗមាន ពង្រូល ពស់ ... និង ខ្លះទៀត ប្រើប្រាស់តែអន្ទាក់សំរាប់ជ្រូកព្រៃ ឈ្លូស ... ។ ការបរបាញ់របស់គេទាំងនោះ ច្រើនប្រព្រឹត្តទៅក្នុងរដូវប្រាំង ឯរដូវវស្សាគេប្រកបរបរធ្វើស្រែ-ចំការជាធម្មតា មានន័យថា ក្នុងចំណោមព្រានទាំង ៧១នាក់ខាងលើមានតែ ២០នាក់ប៉ុណ្ណោះជាព្រានអាជីព ឯ ៥១នាក់ទៀតជាព្រានផង និង ធ្វើកសិកម្មផង ព្រោះការប្រកាន់របរជាព្រានតែមួយមុខ ពុំអាចដោះស្រាយជីវភាពបានទេ ។

- ក្នុងបណ្តាព្រានខាងលើ មានតែព្រាននៅភាគខាងជើងបឹងទន្លេសាប ដែលមានសកម្មភាពប្រមាញ់ខ្ពស់ ព្រោះអ្នកទាំងនោះមានការតាំងទីលំនៅរាយប៉ាយ និង ជាជនជាតិភាគតិចផង ដែលខុសពីព្រាននៅខេត្តកោះកុង ការបរបាញ់ពុំបំរើផ្នែកពាណិជ្ជកម្ម ឬតិចតួចបំផុត ។

- គ្រប់ព្រានទាំងអស់សុទ្ធតែធ្លាប់បានឃើញដានជើង និង ជួបខ្លាដោយផ្ទាល់ក្នុងតំបន់របស់ខ្លួន មួយចំនួនក្នុងនេះ ធ្លាប់បានបរបាញ់សត្វខ្លាទៀតផង ។ ការបរបាញ់សត្វខ្លាធំនេះ បានបង្ហាញពីភាពចៃដន្យរបស់ព្រានច្រើន ជាងពីព្រោះគេម្នាក់ៗចេញទៅបរបាញ់ ពុំបានកំណត់ប្រភេទសត្វទុកជាមុនទេ គឺប្រមាញ់តាមលទ្ធភាពដែល អាចជួប និង ឃើញសត្វ តែក៏មានព្រានមួយចំនួនមិនបរបាញ់ចំពោះប្រភេទសត្វខ្លះដោយមានជំនឿផ្ទាល់ខ្លួន (តម) ហើយនៅតែបន្តប្រពៃណីនេះរៀងរហូត ។ ដោយឡែកផលប្រមាញ់របស់ព្រានម្នាក់ៗ ពុំបានបំរើជីវភាពគ្រួសារគេឱ្យបានគ្រប់គ្រាន់ទេ វាគ្រាន់តែដោះស្រាយម្ហូបអាហារមួយគ្រាៗប៉ុណ្ណោះ តែបើសត្វមានតំលៃខ្លះៗ អាចធ្វើឱ្យគេមានមោទនភាពនឹងបង្កើនរុករកបន្ថែមទៀត ។ ចំពោះបញ្ហានេះ វាហាក់ដូចជាអាស្រ័យនឹងតម្រូវការទីផ្សារដែលជំរុញឱ្យគាត់ជាអ្នកដោះស្រាយប៉ុណ្ណោះ ដូចដែលតួលេខប្រភេទសត្វបានបរបាញ់មាន ពី ១៥-៣០ប្រភេទ ចំពោះព្រានម្នាក់ៗ ក្នុងនោះមាន ត្រកូលគោសាទិស ត្រកូលប្រើស ជ្រូកព្រៃ ពង្រូល មានភាពញឹកញាប់ជាងគេ លើកលែងតែពពួកបក្សី ពុំសូវមានបង្ហាញតួលេខបរបាញ់ ។

ចំពោះចំណេះដឹងរបស់ព្រានលើកិច្ចការការពារសត្វព្រៃ គឺនៅមានកំរិតទាបបំផុត គេពុំដែលបានទទួលការផ្សព្វផ្សាយណាមួយឱ្យបានយល់ពីសារៈប្រយោជន៍នៃសត្វ ឱ្យចេះស្រឡាញ់សត្វ ក្រៅពីវិធានការតឹងរឹងពីរដ្ឋាភិបាលលើមុខរបររបស់ខ្លួន ប៉ុន្តែតាមការសង្កេតដោយផ្ទាល់របស់ក្រុមយើងខ្ញុំឃើញថា គ្រប់អ្នកប្រមាញ់ទាំងនោះបង្ហាញនូវទឹកចិត្តអំណរចំពោះវិធានការទាំងឡាយដែលមានន័យវិជ្ជមាន សំរាប់មូលដ្ឋាន និង តំបន់របស់គេ និងពីភាពចង់ដឹងជាច្រើនដូចជា មូលហេតុនៃការការពារសត្វខ្លាដែលមនុស្សគ្រប់ៗគ្នាយល់ថាជាសត្វសាហាវ និង មានការស្អប់ពីប្រជាជនខ្មែរភាគច្រើន ។ ការចាប់អារម្មណ៍របស់ព្រានចំពោះកិច្ចការពារធនធានសត្វព្រៃ បាន

បង្ហាញពីភាពស្វាគមន៍ច្រើនពីព្រានតាមតំបន់នីមួយៗ ព្រោះសកម្មភាពបរបាញ់កន្លងមក គាត់ដឹងថា ជាទង្វើផ្ទុយ និង វិធានការរដ្ឋាភិបាល តែសំរាប់ជីវភាពអ្នកព្រៃភ្នំ គឺបរបាញ់ ពិតជាពុំអាចជៀសបានដាច់ខាតទេ ដូច្នេះហើយ បានជាមានព្រានមួយចំនួនសំណូមពរលើរាល់បទដ្ឋានច្បាប់សត្វព្រៃ សុំឱ្យមានការបន្ធូរបន្ថយខ្លះៗលើប្រភេទត្រូវប្រមាញ់ ក្នុងន័យដោះស្រាយម្ហូបអាហារ និង ការពារដំណាំ ។

ក្រោយពីបញ្ចប់ដំណើរការសំភាសន៍លើព្រាន និង ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាននីមួយៗ ក្រុមយើងខ្ញុំមានសុទិដ្ឋិនិយមច្រើនចំពោះកិច្ចដំណើរការទៅអនាគតលើប្រធានបទ " ការអភិរក្សសត្វខ្លាធំ " ពីព្រោះជាគន្លឹះសំខាន់មួយដែលយើងអាចធ្វើទៅបាន និង ទទួលផលវិជ្ជមាន ដោយហេតុថា ប្រជាជនមូលដ្ឋានត្រូវការគាំទ្រកិច្ចសហការជាបន្តបន្ទាប់ដូចដែលយើងបានធ្វើក្នុងជំហានទី ២ និង ការបើកសិក្ខាសាលាកន្លងមក ។

៙✹៚